# ម៉ូឌុល ១ៈ

# ការស្វែងយល់ពីអភិបាលកិច្ចល្អ

# ទិសដៅមេរៀន៖



ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹងអាច ៖

- យល់ពីការអនុវត្តន៍ដើម្បីឱ្យមានអភិបាលកិច្ចល្អ តាមរយៈគម្រោងផ្សេងៗនៅកម្ពុជា
- កំណត់បានពីលក្ខណៈនៃសង្គមល្អ និងតួនាទីរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាល ក្នុងការកសាងសង្គមល្អ
- យល់ដឹងអំពីទស្សនទាននៃអភិបាលកិច្ច និងអភិបាលកិច្ចល្អ ឆ្លុះបញ្ចាំងពីការអនុវត្តគម្រោងអភិបាលកិច្ចល្អនៅកម្ពុជា ទៅនឹងទស្សនទាន ទូទៅរបស់អភិបាលកិច្ចល្អ។

# មេរៀនទី១: សង្គមល្អ

# សង្គមល្អ





### តំរូវ ការមូលដ្ឋាន

- សុវត្ថិភាពខាងសេដ្ឋកិច្ច
- សេវាសង្គមដែលល្អ
- សុវត្ថិភាពរូបវន្តនិងមានសន្តិភាព

### ការចូលរួម

- អភិបាលកិច្ចដែលមានការឆ្លើយតប និងរាប់បញ្ចូល
- សិទ្ធិស្មើគ្នា និងយុត្តិធម៌

### ការចងក្រងគ្នា

- គោរពវប្បធម៌ និងមរតកដូនតា
- យកចិត្តទុកដាក់ និងចែករំលែក

# តួនាទីរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាល

**តួនាទីប្រជាពលរដ្ឋ**

- ប្រជាពលរដ្ឋសកម្ម និងរួមដៃគ្នាធ្វើ
- ភាពដឹកនាំរបស់ប្រជាពលរដ្ឋ

⇨ **ការចូលរួម** ⇦

**តួនាទីរដ្ឋាភិបាល**

- ជាអ្នកសម្របសម្រួល

**តួនាទីប្រជាពលរដ្ឋ**

- ប្រជាពលរដ្ឋសកម្ម និងរួមដៃគ្នាធ្វើ
- សាមគ្គីភាពរបស់ប្រជាពលរដ្ឋ
- ភាពដឹកនាំរបស់ប្រជាពលរដ្ឋ

⇨ **ការចងក្រងគ្នា** ⇦

**តួនាទីរដ្ឋាភិបាល**

- ជាអ្នកសម្របសម្រួល
- ជាអ្នកជំរុញ

# តួនាទីរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាល -គ-

**តួនាទីប្រជាពលរដ្ឋ**

- សាមគ្គីភាពរបស់ប្រជាពលរដ្ឋ
- ភាពដឹកនាំរបស់ប្រជាពលរដ្ឋ

⇨ **តម្រូវការមូលដ្ឋាន** ⇦

**តួនាទីរដ្ឋាភិបាល**

- ជាអ្នកសម្របសម្រួល (ខ្លះ)
- ជាអ្នកជំរុញ
- ជាអ្នកផ្ដល់ឱ្យ

# តួនាទីរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាល (ត)



យោងតាមរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា :

ជំពូកទី៤ ស្ដីពី : របបនយោបាយ

ជំពូកទី៥ ស្ដីពី : សេដ្ឋកិច្ច

ជំពូកទី៦ ស្ដីពី : អប់រំ វប្បធម៌ និងសង្គមកិច្ច

# តួនាទីប្រជាពលរដ្ឋ - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា



| តើប្រជាពលរដ្ឋខ្មែរមានសិទ្ធិ និងករណីកិច្ចអ្វីខ្លះ? | មាត្រា |
|---|---|
| ការគោរពសិទ្ធិមនុស្ស | ៣១ |
| សិទ្ធិរស់រានមានជីវិត សេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន | ៣២ |
| សិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត | ៣៤ |
| សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ | ៣៥ |
| សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី | ៣៧ |
| ច្បាប់ហាមឃាត់រង់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ | ៣៨ |

| តើប្រជាពលរដ្ឋខ្មែរមានសិទ្ធិ និងករណីកិច្ចអ្វីខ្លះ? | មាត្រា |
|---|---|
| សិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ | ៣៩ |
| សេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សារព័ត៌មាន បោះពុម្ពផ្សាយ ការប្រជុំ | ៤១ |
| សិទ្ធិបង្កើតសមាគម | ៤២ |
| ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវលប់បំបាត់ចោល | ៤៥ |
| ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ | ៤៩ |

| តើរដ្ឋាភិបាលមានតួនាទីអ្វីខ្លះ? | មាត្រា |
| --- | --- |
| ជំពូកទី៤ : អំពីរបបនយោបាយ | |
| • រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ការពារឯកភាពជាតិ។<br>• រក្សាការពារទំនៀមទំលាប់ នឹងប្រពៃណីល្អរបស់ជាតិ។<br>• ការពារនីត្យានុកូលភាព ធានាសណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ។<br>• យកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ | ៥២ថ្មី |
| ជំពូកទី៥ : អំពីសេដ្ឋកិច្ច | |
| រក្សាការពារបរិដ្ឋាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ | ៥៩ |
| យកចិត្តទុកដាក់ ជួយដោះស្រាយមធ្យោបាយផលិត ការពារផ្លែផលិតផល ជូនកសិករសិប្បករ និងជួយរកទីផ្សារលក់ផលិតផល។ | ៦២ |

| ជំពូកទី៦ : អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច | មាត្រា |
|---|---|
| • ការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាព នៅគ្រប់កំរិត។<br>• យកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។ | ៦៥ |
| សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ។ ប្រជារាស្ត្រ ក្រីក្រ ត្រូវបានទទួលការពិនិត្យរោគដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និង មន្ទីរសម្ភពដល់ជនបទ។ | ៧២ |
| រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែល មានកូនច្រើន ក្នុងបន្ទុកហើយឥតទីពឹង ។ | ៧៣ |

# មេរៀនទី ២:

# ទស្សនទាននៃអភិបាលកិច្ចល្អ

## និយមន័យ:

**អភិបាលកិច្ច** " គឺជាការប្រើប្រាស់នូវសិទ្ធិអំណាចនយោបាយ, សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការជាតិមួយ។ វាគឺជាយន្តការ, ដំណើរការ និង ច្បាប់សាំញ៉ាំ ដែល តាមរយៈនេះ ប្រជាពលរដ្ឋ និងក្រុមផ្សេងៗ បញ្ជាក់ពីផលប្រយោជន៍របស់ខ្លួន,ប្រើប្រាស់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន, និង សម្រុះសម្រួលភាពខ្វែងគំនិតដែលគេមាន។ (UNDP)

អភិបាលកិច្ច គឺជា "..ច្បាប់ទម្លាប់ និងច្បាប់សំខាន់ៗដែលរដ្ឋអំណាចនៃ ប្រទេសមួយ ប្រើប្រាស់ដើម្បីផលប្រយោជន៍រួម។ នេះរួមមាន :

១. ដំណើរការជ្រើសរើស,តាមដាន និងជំនួស អ្នកមានសិទ្ធិអំណាច ។

២. សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវធនធានរបស់ខ្លួន និងអនុវត្ត តាម គោលនយោបាយសមស្រប និង

៣. ការគោរពរបស់ប្រជាពលរដ្ឋ និងរដ្ឋ ចំពោះច្បាប់/ស្ថាប័នដែលគ្រប់គ្រងអន្តរកម្មផ្នែកសេដ្ឋកិច្ច និងសង្គម។" (**ធនាគារពិភពលោក**)

"អភិបាលកិច្ច" គឺជាដំណើរការ ជារបៀបនៃការដឹកនាំ គ្រប់គ្រង ចាត់ចែង ឬ បីបាច់ថែរក្សា និងជាការធ្វើសេចក្ដីសម្រេចចិត្ត និងអនុវត្តសេចក្ដីសម្រេចចិត្តនោះ។ អភិបាលកិច្ចល្អ គឺជាសកម្មភាព ជាដំណើរការ ជារបៀបនៃការដឹកនាំ គ្រប់គ្រង ចាត់ចែង ឬ បីបាច់ថែរក្សា និងជាការធ្វើសេចក្ដីសម្រេចចិត្ត និងអនុវត្តសេចក្ដី សម្រេចចិត្តនោះ ដែលប្រកាន់ភ្ជាប់នូវគោលការណ៍៨រួមមាន: ១) ការចូលរួម ២) ការឆ្លើយតប ៣) គណនេយ្យភាព ៤) ការព្រមព្រៀង ៥) ការតម្លាភាព ៦) សមភាព និងគ្រប់សមាជិកនៃសង្គម ៧) ប្រសិទ្ធភាព-ប្រសិទ្ធផល ៨) គោលការណ៍ច្បាប់-នីតិរដ្ឋ **(គម្រោងអភិបាលកិច្ចល្អមូលដ្ឋាននៃក្រសួង មហាផ្ទៃ)**។

**អភិបាលកិច្ចល្អ** : មានន័យថា មានសមត្ថភាពគ្រប់គ្រងកិច្ចការ និងធនធានរបស់ ប្រទេសជាតិ ប្រកបដោយ**ឆន្ទៈ** មានលក្ខណៈ**បើកចំហ តម្លាភាព គណនេយ្យភាព សមធម៌** និង**ឆ្លើយតប**តម្រូវការរបស់ប្រជាពលរដ្ឋ (UNDP) .

# គោលការណ៍អភិបាលកិច្ចល្អ



ក. អភិបាលកិច្ចល្អគឺផ្តោតលើគោលបំណងរបស់អង្គភាព និងលទ្ធផលសំរាប់ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវាកម្ម។

ខ. អភិបាលកិច្ចល្អគឺជាការអនុវត្តប្រកបដោយប្រសិទ្ធភាព និងមានការកំណត់នូវមុខងារ និងតួនាទីច្បាស់លាស់។

គ. អភិបាលកិច្ចល្អគឺជាការលើកស្ទួយគុណតម្លៃរបស់អង្គភាពទាំងមូល និងបង្ហាញពីគុណតម្លៃរបស់អភិបាលកិច្ចល្អ តាមរយៈការប្រព្រឹត្ត។

ឃ.អភិបាលកិច្ចល្អគឺជាការផ្តល់នូវការជូនដំណឹង ការសំរេចចិត្ត និងការគ្រប់គ្រងហានិភ័យប្រកបដោយ តម្លាភាព។

ង. អភិបាលកិច្ចល្អ គឺជាការបង្កើនសមត្ថភាព និងលទ្ធភាពរបស់អង្គភាពគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។

ច. អភិបាលកិច្ចល្អ គឺជាការគៀងគរអ្នកពាក់ពន្ធ័នានា និងធ្វើឱ្យមានគណនេយ្យភាពពិតប្រាកដ។

# ចរិតលក្ខណៈរបស់អភិបាលកិច្ចល្អ



ក. ការចូលរួម

- ការចូលរួមដោយផ្ទាល់
- ការចូលរួមតាមរយៈអ្នកតំណាង

ខ. នីតិរដ្ឋ

- ក្របខ័ណ្ឌច្បាប់
- ការអនុវត្តច្បាប់ដោយមិនលំអៀង
- ការការពារសិទ្ធិមនុស្ស
- តុលាការឯករាជ្យ និងយុត្តិធម៌
- សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ ដោយមិនលំអៀង និងមិនពុករលួយ

គ. តម្លាភាព

តម្លាភាពត្រូវបានបង្កើតឡើងដោយការផ្តល់ពត៌មានដោយសេរី។ ដំណើរការច្បាប់ និងពត៌មាន អាចផ្តល់ដោយផ្ទាល់ដល់អ្នកដែលត្រូវការវា និងផ្តល់ពត៌មានគ្រប់គ្រាន់ ដើម្បីស្វែងយល់ និងត្រួតពិនិត្យ តាមដាននូវ ពត៌មានទាំងនោះ។

## ឃ. ការឆ្លើយតប

នៅក្នុងការអនុវត្តន៍អភិបាលកិច្ចល្អ របស់រដ្ឋាភិបាល បណ្តាភ្នាក់ងារ ផ្តល់សេវាបានទាន់ពេលវេលា និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ម្ចាស់ឆ្នោត។

## ង. ការព្រមព្រៀង

ចំណាប់អារម្មណ៍ និងមតិយោបល់ មានភាពខុសគ្នាក្នុងគ្រប់សង្គមនិមួយៗ។ អភិបាលកិច្ចល្អខិតខំយ៉ាងខ្លាំង ដើម្បីសម្រុះសម្រួលភាពខុសគ្នាទាំងនេះឱ្យក្លាយជាមតិទូទៅរួមមួយចំពោះអ្វីដែលល្អបំផុត ដើម្បី សំរេចរាល់កិច្ចការទាំងអស់។

## ច. សមធម៌

គ្រប់បុរសនិងស្ត្រីមិនប្រកាន់អាយុ យេនឌ័រ ឬស្ថានភាពនៅក្នុងជីវិតរស់នៅ សុទ្ធតែមានឱកាស ដើម្បីពង្រីក ឬ

រក្សានូវភាពកម្រមក្សាន្ត របស់គេ។

## ឆ. ប្រសិទ្ធភាព និងប្រសិទ្ធផល

- រដ្ឋាភិបាលដែលបាននឹងកំពុងអនុវត្តអភិបាលកិច្ចល្អ បង្កើតលទ្ធផលដែល សមស្រប និងសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋ ដោយប្រើប្រាស់ធនធានបានយ៉ាងប្រសើរ។

ជ. គណនេយ្យភាព

ក្នុងអភិបាលកិច្ចល្អ អ្នកធ្វើសេចក្តីសំរេចចិត្តក្នុងរដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិលអាច ឆ្លើយទៅសាធារណជនផង និងទៅស្ថាប័នពាក់ពន្ធ័នានាផង។

# ទស្សនទាននៃអភិបាលកិច្ចបែបប្រជាធិបតេយ្យ

អភិបាលកិច្ចបែបប្រជាធិបតេយ្យ: សំដៅលើការគ្រប់គ្រងកិច្ចការក្នុងសង្គម ដោយផ្អែកលើគោលការណ៍ជាសកលរបស់លទ្ធិប្រជាធិបតេយ្យដែលជាប្រពន្ធ័ច្បាប់ ដើម្បីធ្វើឱ្យ:

- ប្រជាពលរដ្ឋ មាន**ការយល់ព្រម** និង**ចូលរួមជាអតិបរមា**
- អ្នកគ្រប់គ្រង**គោរពច្បាប់** និងមាន **គណនេយ្យភាព** និងមានការ**ឆ្លើយតប**ទៅនឹងផលប្រយោជន៍ និងតម្រូវការ របស់សាធារណជន ។

# ទស្សនទាននៃអភិបាលកិច្ចបែបប្រជាធិបតេយ្យ (ត)



មូលដ្ឋានគ្រឹះនៃអភិបាលកិច្ចបែបប្រជាធិបតេយ្យ

គឺប្រទេសមួយត្រូវ:

- មានការបោះឆ្នោតដោយសេរី និងយុត្តិធម៌
- មានគណបក្សច្រើន ដែលរៀបចំបានល្អក្នុងការប្រកួតប្រជែងគ្នា និងសមហេតុផល
- ពណ៌នាឱ្យមានការយល់ដឹង ការគោរពនិង ការការពារសេរីភាពជនស៊ីវិល និងសិទ្ធិមនុស្សក្នុងសង្គម និង
- មានការជំរុញ គាំទ្រ និងចូលរួមសកម្មពីសង្គមស៊ីវិលដែលមានចំណាប់អារម្មណ៍ខ្លាំងក្លា។

ដំណើរការអភិបាលកិច្ចល្អឱ្យមានចេរភាព ចាំបាច់ត្រូវ **អនុវត្តលទ្ធិប្រជាធិបតេយ្យ** ដែលផ្តល់ឱកាសច្រើនឱ្យ :

- ប្រជាពលរដ្ឋ បានចូលរួម
- មានក្រុមឯករាជ្យលេចចេញឡើង
- មាន គណបក្សប្រឆាំង កកើតឡើងហើយ
- ពលរដ្ឋម្នាក់ៗអាចអនុវត្ត និងដកស្រង់បទពិសោធន៍ ក្នុងការជ្រើសរើស ដោយសេរីនៅសង្គមមានអភិបាលកិច្ចបែបប្រជាធិបតេយ្យ។

មូលហេតុទាំងនេះ ហើយ ដែលនាំឱ្យ **ប្រជាធិបតេយ្យ**ក្លាយខ្លួនជា**យុទ្ធសាស្រ្តដ៏សំខាន់**ក្នុងការធ្វើឱ្យមាន**អភិបាលកិច្ចល្អ** ក្នុងសង្គម។

# អភិបាលកិច្ចបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ



| អភិបាលកិច្ចល្អ | អភិបាលកិច្ចបែបប្រជាធិបតេយ្យ |
|---|---|
| • ការចូលរួម<br>• នីតិរដ្ឋ<br>• តម្លាភាព<br>• ការឆ្លើយតប<br>• មតិឯកច្ឆ័ន្ទ<br>• សមធម៌<br>• ប្រសិទ្ធភាព និងប្រសិទ្ធផល<br>• គណនេយ្យភាព | • ការបោះឆ្នោតដោយសេរី និងយុត្តិធម៌<br>• មានប្រព័ន្ធគណបក្សដែលរៀបចំបានល្អ និងសមហេតុផល និងមានការប្រកួតប្រជែង<br>• បង្ហាញនូវការគោរព និងការពារសេរីភាពជនស៊ីវិល និងសិទ្ធមនុស្ស និង<br>• ជំរុញគាំទ្រការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិលជាពិសេសក្រុមមានចំណាប់អារម្មណ៍ខ្លាំងក្លា ។ |

## ❑ រដ្ឋបាលថ្នាក់មូលដ្ឋាន/ក្រោមជាតិ

រដ្ឋបាលថ្នាក់មូលដ្ឋាន/ក្រោមជាតិមាន រាជធានី/ខេត្ត/ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ស្រុកប្រតិបត្តិ។ល។ រដ្ឋបាលថ្នាក់ មូលដ្ឋាន/ក្រោមជាតិចែកជា៖

- រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រប់គ្រង និងដំណើរការការងារ របស់ថ្នាក់ មូលដ្ឋាន/ក្រោមជាតិ ជារៀងរាល់ថ្ងៃ ជា**គណៈអភិបាល** (ជ្រើសរើសផ្ទាល់ ប្រយោល ឬចាត់តាំង ដោយរដ្ឋបាល ជាន់ខ្ពស់) ។
- ក្រុមអ្នកតំណាងមូលដ្ឋាន/ថ្នាក់ក្រោមជាតិ៖ជា**ក្រុមប្រឹក្សា**រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ។

## ❑ អភិបាលកិច្ចថ្នាក់មូលដ្ឋាន/ក្រោមជាតិ

អភិបាលកិច្ចថ្នាក់មូលដ្ឋាន/ក្រោមជាតិរួមមានសំណុំច្បាប់ យន្តការនិងដំណើរការ ដែលធ្វើឱ្យប្រជាពលរដ្ឋ និងក្រុមអាចបញ្ចេញនូវចំណាប់អារម្មណ៍ និងតំរូវការរបស់គេ សម្រុះសម្រួលភាពចំរូងចំរាស់គ្នា និង អនុវត្តនូវសិទ្ធិនិង កាតព្វកិច្ចរបស់គេនៅថ្នាក់មូលដ្ឋាន/ក្រោមជាតិ។

**មូលដ្ឋានគ្រឹះនៃអភិបាលកិច្ចល្អ**មាន៖ **ការចូលរួម**របស់ពលរដ្ឋ **ភាពជាដៃគូ**របស់តួអង្គសំខាន់ៗនៅថ្នាក់ក្រោមជាតិ **សមត្ថភាព**របស់តួអង្គនៅគ្រប់ផ្នែក **ចរន្តពត៌មានសំបូរបែប** **គណនេយ្យភាព** នៃស្ថាប័ន និង**ការផ្តោតផ្តោះ ទៅរកអ្នកក្រីក្រ**។

# ភាពខុសគ្នារវាងអភិបាលកិច្ចថ្នាក់ក្រោមជាតិ ទៅនិងអភិបាលកិច្ចល្អ



| អភិបាលកិច្ចល្អ | អភិបាលកិច្ចថ្នាក់ក្រោមជាតិ |
|---|---|
| ការចូលរួម | ប្រជាធិបតេយ្យភាវូបនីយកម្ម : វិមជ្ឈការអំណាចនយោបាយ |
| មតិឯកច្ឆ័ន្ទ | និន្នាការធ្វើឱ្យអ្នកមូលដ្ឋានសំរុះសំរួលគ្នាលើគំនិតខុសៗគ្នា |
| គណនេយ្យភាព | គណនេយ្យភាពចំពោះប្រជាពលរដ្ឋ |
| តម្លាភាព | មានទំនាក់ទំនងគ្នា និងចរន្តព័ត៌មានចំរុះ |
| ការឆ្លើយតប | នៅជិតប្រជាពលរដ្ឋ និងតំរូវការរបស់គេ(ដឹងសុខទុក្ខ) |
| ប្រសិទ្ធភាព | បើសិនមុខងារហិរញ្ញវត្ថុ និងមន្ត្រីសាធារណៈដែលមានសមត្ថភាពត្រូវផ្តល់អំណាចឱ្យទាំងស្រុង |
| សមធម៌ | មានគោលនយោបាយគាំទ្រដល់ពលរដ្ឋក្រីក្រ |
| នីតិរដ្ឋ (អនុវត្ត) | ក្របខ័ណ្ឌច្បាប់មូលដ្ឋានជាមួយវិមជ្ឈការនយោបាយ |

# ចំណុចសំខាន់ៗនៃម៉ូឌុលៈ អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អជា  នៃយុទ្ធសាស្ត្រចតុកោណ

# សូមអរគុណ

## ចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោកអ្នក

